01335803

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / 10 / 2016
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦

## សវនាការលើអង្គសេចក្តី - ថ្ងៃ ៤៥៧

រៀបចំដោយ៖ លោកស្រី សែ កុលវុឌ្ឍី និង កញ្ញា Evelyn CAMPOS SANCHEZ

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោកស្រី Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Joseph Andrew Boyle, លោក Vincent de Wilde d'Estmael, កញ្ញា Nisha PATEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក លីវ សុវណ្ណា, កញ្ញា Doreen CHEN |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ, កញ្ញា Soumeya MEDJEBEUR, និង កញ្ញា អ៊ុច ស្រីផាត់ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, និង លោក Calvin SAUNDERS |

| | |
|---|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោកស្រី ទី ស្រ៊ីនណា, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ លោកស្រី ហេង ឡៃហ៊ាង (2-TCCP -251) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្នួរ សុទ្ធាវី |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, កញ្ញា Georgina QUINTON SMITH, លោក កែវ វ៉ាត, លោក នូ មនោរ័ត្ន, លោក Sheriffo JAMMEH, កញ្ញា ស្រី ណាក់, លោក ខៀវ ម៉ាឌី |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ | ចាប់ផ្ដើមម៉ោង៖ ០៩.០៨ | បញ្ចប់ម៉ោង៖ ១៦.១៧ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៨ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៤ | បញ្ចប់ម៉ោង៖ ១៥.០៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ៣៦ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៨ | ០៩.១០ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១០ | ០៩.១២ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី លោកស្រី ហេង ឡៃហ៊ាង (2-TCCP-251) តាមរយៈប្រព័ន្ធសោតទស្សន៍ | អង្គជំនុំជម្រះ<br><br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន<br>សេចក្ដីថ្លែងទុក្ខសោករបស់ | ០៩.១៣<br>១៤.២១<br>០៩.១៨<br><br>១១.០២<br>១៣.៣០<br>១៥.០៣<br>១៦.១០ | ០៩.១៧<br>១៤.៤៤<br>១១.០២<br><br>១១.៣៧<br>១៤.២០<br>១៦.១០<br>១៦.១៦ |

| | | | |
|---|---|---|---|
| | ដើមបណ្ដឹងរដ្ឋប្បវេណី | | |
| សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា តាមវិធាន ៨៧.៤ សុំឱ្យទទួលយកជាឯកសារភ័ស្ដុតាង (E416) | អង្គជំនុំជម្រះ | ១០.៣០ | ១០.៣៤ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែលោក លោក Victor Koppe មេធាវីការពារក្ដីលោក នួន ជា អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង (2-TCCP-251) តាមរយៈប្រព័ន្ធសោតទស្សន៍</u>**

ប្រធានអង្គជំនុំជម្រះ បានតាំងសំណួរបឋម និង ប្រាប់ពីសិទ្ធិ និងករណីកិច្ចសំខាន់ៗទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-251។ បន្ទាប់មក មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង (2-TCCP-251) ។

**<u>សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដី នួន ជា តាមវិធាន ៨៧.៤ សុំឱ្យទទួលយកឯកសារចំនួន ៤ ជាឯកសារភ័ស្ដុតាង (E416)</u>**

អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលមេធាវីការពារក្ដី នួន ជា បានដាក់នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារចំនួនបួន ជាឯកសារភ័ស្ដុតាង (ឯកសារ **E416**)។ នៅក្នុងសំណើនោះ គឺស្នើសុំឱ្យទទួលយកឯកសារខាងក្រោមជាភ័ស្ដុតាង៖

(១) ប្រតិចារឹកនៃបទសម្ភាសន៍ជាមួយសាក្សីដែលមិនស្គាល់អត្តសញ្ញាណចំនួនបួននាក់ ដែលលោក រ៉ូប៊ឺត លឹមឃីន (Robert LEMKIN) (2-TCW-877) និងលោក ថេត សម្បត្តិ (2-TCW-885) បានសម្ភាសន៍ដើម្បី ផលិតជាខ្សែភាពយន្តរបស់ពួកគាត់ដែលមានចំណងជើងថា "សត្រូវប្រជាជន" (ឯកសារ **F2/4/3/3/6.2**)។

(២) កំណត់ហេតុដែលលោក លឹម ឃីន (LEMKIN) បានសរសេរពាក់ព័ន្ធនឹងបទសម្ភាសន៍ទាំងនេះ (ឯកសារ **F2/4/3/3.1**)។

(៣) កំណត់ហេតុស្តាប់ចម្លើយរបស់លោក លឹម ឃីន (LEMKIN) នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល (ឯកសារ **F2/4/3/1**)។ និង

(៤) អត្ថបទមួយដែលបានចុះផ្សាយនៅក្នុងសារព័ត៌មាន ខេមបូឌាដេលី វីកឃែន (*Cambodia Daily Weekend*) ចុះផ្សាយនៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៦ (ឯកសារ **E416/3.1.2**)។

នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើ (ឯកសារ **E416/1**) ហើយសហមេធាវីនាំមុខបានដាក់ចម្លើយតប នៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ (ឯកសារ **E416/2**)។ មេធាវីការពារក្តី នួន ជា បានឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦ (ឯកសារ **E416/3**)។

បន្ទាប់ពីបានពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់ភាគីនានា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយរបស់លោក LEMKIN គឺឯកសារ **F2/4/3/1** ត្រូវបានទទួលយកជាឯកសារភស្តុតាងរួចហើយនៅក្នុងសំណុំរឿង ០០២/០២ ដែលមានលេខឯកសារ **E3/9620**។ ហេតុនេះសំណើពាក់ព័ន្ធនឹងឯកសារនេះត្រូវចាត់ទុកជាអសារបង់។

ចំពោះប្រតិចារឹកដែលមានលេខឯកសារ **F2/4/3/3/6.2** អង្គជំនុំជម្រះទទួលយកជាភស្តុតាងត្រឹមតែកិច្ចសម្ភាសន៍ជាមួយសាក្សីដែលត្រូវបានកំណត់លេខ **W2** ប៉ុណ្ណោះ ដែលត្រូវបានជឿជាក់ថាជាសាក្សី ទាត់ ធឿន (**2-TCW-829**) ផ្អែកតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឯកសារ **F2/9**។ ហេតុដូចនេះ អង្គជំនុំជម្រះទទួលយកនូវសម្រង់នៃប្រតិចារឹក ដែលមានលេខឯកសារ **F2/9.2** ហើយកំណត់ជាលេខឯកសារ **E3/10665**។

អង្គជំនុំជម្រះសម្រេចបដិសេធផ្នែកផ្សេងទៀតនៃសំណើសុំរបស់មេធាវីការពារក្តី នួន ជា ទាំងស្រុងហើយសំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះនឹងចេញនៅពេលក្រោយ។

## New E3s

| TC No | | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10665 | F2/9.2 | 01168433-01168486<br>01156796-01156827<br>/ | Annex 2: Interviews of TOAT Thoeun with TETH Sambath and Robert LEMKIN, 21 October 2015 | P | / | / | / |

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/436 | / | 00405484-00405495<br>00414561-00414572<br>00424142-00424153 | Written record of interview of Civil Party HENG Lai Heang/SA Lai Heang | P | 00405490<br>00405491<br>00405488<br>00405489<br>00405487<br>00405494 | 00414567<br>00414568<br>00414585<br>00414566<br>00414564<br>00414671 | 00424148<br>/<br>00424146<br>00424147<br>00424145<br>00424152 |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10604 | / | /<br>01222328-01222936<br>/ | Annex 2: OCIJ S-21 Prisoners List 31 March 2016 | P | / | 01222336 | / |
| E3/765 | / | 00376472-00376507<br>00539976-00540007<br>00540008-00540037 | Revolutionary Youth Number 10 October 1978 | P | 00376493-4 | 00539994 | 00540024-5 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១២)

- សេចក្តីសម្រេចទទួលយកឯកសារ F2/4/3/3/6.2 ធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន ៨៧.៤ ដែលកំណត់លេខសំគាល់ E3/10665។ (១០.៣៤)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦។ (១៦.១៧)

| កាលវេលាសវនាការបន្ត |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦

ក្រឡាបញ្ជី

ស៊ែ CAMPOS SANCHEZ